**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២០២ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១០៦ អនក្រ. បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ស្តីពីការធានារ៉ាប់រង
- យោង តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះមានគោលបំណង ផ្តល់នីតិសម្បទាដល់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ឱ្យធ្វើសកម្មភាពធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបង្កើតនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច។

**ប្រការ ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពអាជីវកម្មធានារ៉ាប់រងខ្នាតតូចទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣._**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ក្រុមហ៊ុន** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដែលមានសិទ្ធិធ្វើអាជីវកម្មធានារ៉ាប់រងខ្នាតតូចស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **សាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុក** សំដៅដល់សាខារបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចដែលបានទទួល អាជ្ញាបណ្ណប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច នៅបណ្តារាជធានី ខេត្ត ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា។
- **នីតិបុគ្គលប្រតិស្រុត** សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ក្រុមហ៊ុនបុត្រសម្ព័ន្ធ** សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ"។
    - ក). បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺក្រុមហ៊ុនសហកម្មសិទ្ធិមេនោះកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ។
    - ខ). បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនគឺក្រុមហ៊ុនមូលធនមេនោះ ត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន។

## ជំពូកទី ២
## ការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច

**ប្រការ ៤._**

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែជានីតិបុគ្គលប្រតិស្រុតក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងត្រូវមានសមាសភាពភាគទុនិកយ៉ាងតិចចំនួន ០៣ (បី)។

**ប្រការ ៥._**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូចជាក្រុមហ៊ុនបង្កើតថ្មី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចមកក្រសួង។ មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម÷

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច
- ឯកសារសិក្សាសមិទ្ធលទ្ធភាពនៃទីផ្សារធានារ៉ាប់រងខ្នាតតូចនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ០៥ (ប្រាំ) ឆ្នាំ
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិក÷ ជារូបវន្តបុគ្គល ត្រូវផ្តល់លិខិតឆ្លងដែន ឬអត្តសញ្ញាណ-បណ្ណថតចម្លង ឬជានីតិបុគ្គល ត្រូវផ្តល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល
- ឯកសារថតចម្លង បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គល ដែលត្រូវតែងតាំងជាប្រធាន និងសមាជិកក្រុម-ប្រឹក្សាភិបាល។ ឯកសារមានជាអាទិ៍÷ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណថតចម្លង ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ
- ឯកសារបញ្ជាក់នាមករណ៍បម្រុងទុករបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញលិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើសំណើសុំក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ ក្រសួងចេញជូនលិខិតអនុញ្ញាតជាគោលការណ៍នេះ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៦._**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច និងបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម÷

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដែលចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញ និងចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុម-ប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដែលចេញដោយក្រសួង
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង
- ឯកសារអំពីគោលការណ៍ធានារ៉ាប់រងបន្ត
- ឯកសារអំពីគោលការណ៍អភិបាលកិច្ច
- ឯកសារអំពីគោលការណ៍ណែនាំគណនេយ្យ
- ឯកសារអំពីគោលការណ៍ណែនាំស្តីពីការកំណត់តម្លៃ និងហានិភ័យ
- ឯកសារអំពីគោលការណ៍ណែនាំស្តីពីការទប់ស្កាត់ និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ឯកសារអំពីគោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហានិភ័យផ្សេងទៀត
- ឯកសារបញ្ជាក់ដើមទុនអប្បបរមា
- ឯកសារបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្ម
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ថតចម្លង
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ថតចម្លង ដោយមានបញ្ជាក់នីត្យានុកូលភាពពីសាលារាជធានី ខេត្ត
- លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មពីអាជ្ញាធរមូលដ្ឋាន
- ឯកសារថតចម្លង បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជា អគ្គនាយក និងអ្នកជំនាញគណនាហានិភ័យ និងបុព្វលាភធានារ៉ាប់រង មានជាអាទិ៍÷ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ ការសិក្សា ដោយភ្ជាប់សញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ ដោយមានការបញ្ជាក់ពីក្រុមហ៊ុន និងព្រឹត្តិបត្រថ្កោលទោសច្បាប់ដើម ឬថតចម្លងដោយមានបញ្ជាក់ពីសារការី។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច ឬបដិសេធសំណើសុំអាជ្ញាបណ្ណក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ ៧._**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូចជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសាខាក្រុមហ៊ុនបរទេស ត្រូវផ្តល់ឯកសារដូចមានចែងក្នុងប្រការ៥ និងប្រការ៦ និងត្រូវបន្ថែមឯកសារដូចខាងក្រោម÷

១. សំណើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដែលចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- ព័ត៌មានអំពីប្រវត្តិសង្ខេបនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធ
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធសម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ តាមការចាំបាច់
- ព័ត៌មានស្តីពីចំណាត់ថ្នាក់របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធនៅក្នុងប្រទេសដើម និងក្នុងសកលលោក ដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ជាអន្តរជាតិ
- ឯកសារអំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធ។

២. សំណើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច

- លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណប្រកបអាជីវកម្ម របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនពាក់ព័ន្ធ អនុញ្ញាតឱ្យប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូចក្នុងព្រះរាជាណាចក្រកម្ពុជា
- លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ឱ្យប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច ឬបដិសេធលើសំណើសុំអាជ្ញាបណ្ណក្នុងរយៈពេល និងតាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ៥ និងប្រការ៦។

**ប្រការ ៨._**

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចជាបុត្រសម្ព័ន្ធដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោមអាជ្ញាបណ្ណបណ្តោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូច ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចមកក្រសួង ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន នៃថ្ងៃផុតសុពលភាពអាជ្ញាបណ្ណបណ្តោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូចរបស់ក្រុមហ៊ុន ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម÷

- លិខិតស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញ និងចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- ច្បាប់ចតចម្លងអាជ្ញាបណ្ណបណ្ដោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូច (សន្លឹកអាជ្ញាបណ្ណដើម នឹងត្រូវយកមកប្ដូរនៅពេលផ្ដល់ជូនអាជ្ញាបណ្ណថ្មី)
- ឯកសារអំពីផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ
- ឯកសារបញ្ជាក់ការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ
- បណ្ណប៉ាតង់ប្រចាំឆ្នាំក្រោយគេបំផុត

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចជាបុត្រសម្ព័ន្ធ ដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោមអាជ្ញាបណ្ណបណ្ដោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូច បាន ឬមិនបានស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃផុតសុពលភាពនៃអាជ្ញាបណ្ណបណ្ដោះអាសន្ន ត្រូវទទួលពិន័យអន្តរការណ៍ក្នុងប្រកាសនេះ ហើយផុតរយៈពេលកំណត់នេះ ត្រូវចាត់ទុកថាក្រុមហ៊ុនធ្វើអាជីវកម្មធានារ៉ាប់រងខ្នាតតូចដោយគ្មានអាជ្ញាបណ្ណ និងត្រូវទទួលទោសតាមច្បាប់ស្ដីពីការធានារ៉ាប់រង។

**ប្រការ ៩._**

អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចមានសុពលភាពអចិន្ត្រៃយ៍ចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ ដោយក្រុមហ៊ុនត្រូវបង់កម្រៃអាជ្ញាបណ្ណជារៀងរាល់ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬ លក់បានឡើយ។

**ប្រការ ១០._**

ក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិបង្កើតសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុក ដោយត្រូវស្នើសុំវិញ្ញាបនបត្រសាខាមកក្រសួង។ មុននឹងស្នើសុំបង្កើតសាខាណាមួយ ក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មធានារ៉ាប់រងខ្នាតតូចរបស់សាខានោះ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម÷

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍បង្កើតសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុក
- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ឯកសារអំពីការសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សាររបស់សាខាក្រុមហ៊ុន
- ឯកសារអំពីផែនការអាជីវកម្មរយៈពេល ០៣ (បី) ឆ្នាំ

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញការអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើសំណើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ ក្រសួងចេញជូនលិខិតអនុញ្ញាតជាគោលការណ៍នេះ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ១១._**

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាគោលការណ៍ និង បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវស្នើសុំវិញ្ញាបនបត្រសាខាមកក្រសួង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំវិញ្ញាបនបត្រសាខា ដែលចុះហត្ថលេខាដោយប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- លិខិតអនុញ្ញាតជាគោលការណ៍ក្នុងការបង្កើតសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុក ដែលចេញដោយក្រសួង
- ឯកសារថតចម្លង បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានសាខា មានជាអាទិ៍៖ លិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ ថតចម្លង ប្រវត្តិរូបសង្ខេបស្តីពីបទពិសោធន៍ការងារ ការសិក្សា ដោយភ្ជាប់សញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ ដោយមានការបញ្ជាក់ពីក្រុមហ៊ុន និងព្រឹត្តិបត្រថ្កោលទោសច្បាប់ដើម ឬថតចម្លងដោយមានបញ្ជាក់ពីសារការី
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ថតចម្លង ដោយមាននីត្យានុកូលកម្មពីសាលារាជធានី ខេត្ត
- បណ្ណប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លិខិតបញ្ជាក់ទីតាំងប្រកបអាជីវកម្មពីអាជ្ញាធរមូលដ្ឋាន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រងសាខាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ ក្រសួងមានសិទ្ធិសម្រេចចេញវិញ្ញាបនបត្រសាខាក្រុមហ៊ុន ឬបដិសេធលើសំណើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលលិខិតស្នើសុំ ដែលមានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ ១២._**

វិញ្ញាបនបត្រសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុកមានសុពលភាពអចិន្ត្រៃយ៍ដោយក្រុមហ៊ុន ត្រូវបង់កម្រៃវិញ្ញាបនបត្រសាខាជារៀងរាល់ឆ្នាំ ។ វិញ្ញាបនបត្រនេះមិនអាចផ្ទេរ ឬ លក់បានឡើយ។

**ប្រការ ១៣._**

ក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួង រាល់ពេល ផ្លាស់ប្តូរ ឬកែប្រែនាមករណ៍ ឬព័ត៌មានអាសយដ្ឋាន ឬសមាសភាពភាគទុនិក និងក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន ឬសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចក្នុងស្រុក។

## ជំពូកទី ៣

## កម្រៃអាជ្ញាបណ្ណ និងសោហ៊ុយពាក់ព័ន្ធ

**ប្រការ ១៤._**

ក្រុមហ៊ុនត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ ចំនួន ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ចូលគណនីទោលរតនាគារ ជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា ឬគណនីរបស់ធនាគារដៃគូ។

ក្រុមហ៊ុនត្រូវបង់កម្រៃវិញ្ញាបនបត្រប្រចាំឆ្នាំ ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល ចូលគណនីទោលរតនាគារ ជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា ឬគណនីរបស់ធនាគារដៃគូ។

**ប្រការ ១៥._**

ក្រុមហ៊ុនត្រូវបង់កម្រៃអាជ្ញាបណ្ណ ឬកម្រៃវិញ្ញាបនបត្រប្រចាំឆ្នាំ យ៉ាងយូរថ្ងៃទី៧ ខែមករា ដើមឆ្នាំប្រតិបត្តិការអាជីវកម្ម។

**ប្រការ ១៦._**

ក្រុមហ៊ុនត្រូវបង់ប្រាក់ភាគទាន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយ នៃបុព្វលាភដុល ជាប្រចាំខែ ចូលមូលនិធិអភិវឌ្ឍន៍វិស័យធានារ៉ាប់រងឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់។

## ជំពូកទី ៤

## ពិន័យអន្តរការណ៍

**ប្រការ ១៧._**

ត្រូវពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចជាបុត្រសម្ព័ន្ធ ដែលកំពុងប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោមអាជ្ញាបណ្ណបណ្តោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូចណាដែលបាន ឬមិនបានស្នើសុំអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូច ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិនបន្ទាប់ពីថ្ងៃផុតសុពលភាពនៃអាជ្ញាបណ្ណបណ្តោះអាសន្ន ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ ដូចខាងក្រោម÷

- ចំពោះករណីយឺតចាប់ពី ០១ (មួយ) ថ្ងៃ ដល់ ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន ២ ០០០ ០០០(ពីរលាន) រៀល ក្នុងមួយថ្ងៃ និងត្រូវស្នើសុំជាបន្ទាន់
- ចំពោះករណីយឺតចាប់ពី ០៤ (បួន) ថ្ងៃ ដល់ ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន

៤ ០០០ ០០០(បួនលាន) រៀល ក្នុងមួយថ្ងៃ និងត្រូវស្នើសុំជាបន្ទាន់

- ចំពោះករណីយឺតចាប់ពី ០៨ (ប្រាំបី) ថ្ងៃ ដល់ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រុមហ៊ុនត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង

**ប្រការ ១៨._**

ត្រូវពិន័យអន្តរការណ៍ជាទឹកប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ក្នុង ១ (មួយ) ករណី និងត្រូវស្នើសុំមកក្រសួងជាបន្ទាន់ ចំពោះក្រុមហ៊ុនណាដែលមិនបំពេញកាតព្វកិច្ចស្នើសុំមកក្រសួងអំពីការផ្លាស់ប្តូរ ឬកែប្រែនាមករណ៍ ឬព័ត៌មានអាសយដ្ឋាន ឬសមាសភាពភាគទុនិក និងក្រុមប្រឹក្សាភិបាលដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ។

ក្នុងករណីមិនរាងចាល ក្រុមហ៊ុនត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង។

**ប្រការ ១៩._**

ត្រូវពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនណាដែលមិនបំពេញកាតព្វកិច្ចបង់កម្រៃអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រប្រចាំឆ្នាំតាមកាលបរិច្ឆេទកំណត់ ដូចមានចែងក្នុងប្រការ ១៥ នៃប្រកាសនេះ ដូចខាងក្រោម÷

- ចំពោះករណីយឺតចាប់ពី ០១ (មួយ) ថ្ងៃ ដល់ ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន ២ ០០០ ០០០(ពីរលាន) រៀល ក្នុងមួយថ្ងៃ
- ចំពោះករណីយឺតចាប់ពី ០៤ (បួន) ថ្ងៃ ដល់ ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន ៤ ០០០ ០០០(បួនលាន) រៀល ក្នុងមួយថ្ងៃ
- ចំពោះករណីយឺតចាប់ពី ០៨ (ប្រាំបី) ថ្ងៃ ដល់ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រុមហ៊ុនត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង
- ចំពោះករណីយឺតលើសពី ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ អាជ្ញាបណ្ណរបស់ក្រុមហ៊ុននឹងលែងមានសុពលភាព និងត្រូវចាត់ទុកថាធ្វើអាជីវកម្មធានារ៉ាប់រងខ្នាតតូចដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ ២០._**

ត្រូវពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនណាដែលមិនបំពេញកាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំខែ ដូចមានចែងក្នុងប្រការ ១៦ នៃប្រកាសនេះ ដូចខាងក្រោម÷

- ចំពោះករណីយឺតចាប់ពី ០១ (មួយ) ថ្ងៃ ដល់ ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន ៥០០ ០០០ (ប្រាំរយពាន់) រៀល ក្នុងមួយថ្ងៃ
- ចំពោះករណីយឺតចាប់ពី ០៤ (បួន) ថ្ងៃ ដល់ ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ត្រូវពិន័យជាប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ក្នុងមួយថ្ងៃ

- ចំពោះករណីយឺតលើសពី ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រុមហ៊ុនត្រូវទទួលទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងច្បាប់ស្ដីពីការធានារ៉ាប់រង។

**ប្រការ ២១._**

ក្រុមហ៊ុនត្រូវបង់ប្រាក់ពិន័យចូលគណនីទោលរតនាគារ ជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា ឬគណនីរបស់ធនាគារដៃគូ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**ប្រការ ២២._**

អាជ្ញាបណ្ណបណ្ដោះអាសន្នអាជីវកម្មធានារ៉ាប់រងខ្នាតតូច ដែលនៅមានសុពលភាព ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់ផុតសុពលភាព។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ២៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែ[illegible] ឆ្នាំ២០២១*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង/ស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការ ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ